ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ញត្តិកម្ម

ចែករំលែកដោយៈ មេធាវីគម្រាច្បាប់
www.legalcodecambodia.com
www.facebook.com/legalcodelawoffice
App Store & Play Store: LEGAL CODE LIBRARY (បណ្ណាល័យគម្រាច្បាប់)

នៅក្នុងដំណើរការសន្ទានកម្ម សន្ទានការីគ្រាន់តែជាអ្នកជួយសំរួលភាពតានតឹងរវាងភាគី និងជាអ្នកជួយផ្តល់នូវជំរើសក៏ដូចជាដំណោះស្រាយជូនភាគីប៉ុណ្ណោះ។ សន្ទានការីគ្មានសិទ្ធិក្នុងការចាប់បង្ខំអោយភាគីទទួលយកដំណោះស្រាយណាមួយដែលពួកគេមិនពេញចិត្តឡើយ។ នៅក្នុងដំណើរការនេះលទ្ធផលគឺត្រូវគ្រប់គ្រង ដោយភាគីវិវាទសន្ទានការីគ្មានសិទ្ធិក្នុងការចេញសេចក្តីសំរេចសំរាប់ភាគីនោះទេ។ ចំពោះរាល់ការសំរេចផ្សេងៗ គឺភាគីជាអ្នកដែលមានសិទ្ធិក្នុងការធ្វើសេចក្តីសំរេចលើវិវាទរបស់ខ្លួន។

### III. មជ្ឈត្តការ

មជ្ឈត្តការ គឺជាវិធីសាស្រ្តដោះស្រាយវិវាទចំបងទី៣ ( ការចរចា សន្ទានកម្ម និង មជ្ឈត្តការ )។ នៅក្នុងមជ្ឈត្តការគូភាគីដាក់វិវាទរបស់ខ្លួនជូនទៅភាគីទី៣ ដែលអព្យាក្រឹត្យមួយ។ ភាគីទី៣ នេះពិចារណាអំពីភស្តុតាង ដែលភាគីវិវាទបានដាក់ជូន និងចេញសេចក្តីសំរេចមួយហៅថា មជ្ឈត្តវិនិច្ឆ័យ។ មជ្ឈត្តវិនិច្ឆ័យ ជាទូទៅមានភ្ជាប់កាតព្វកិច្ចចំពោះភាគីទាំងអស់តែយ៉ាងណាមិញ ក្នុងករណីខ្លះ មជ្ឈត្តវិនិច្ឆ័យ ក៏អាចមិនភ្ជាប់កាតព្វកិច្ចចំពោះភាគីដែរ។

#### ១. ប្រវត្តិនៃមជ្ឈត្តការ

មជ្ឈត្តការមានប្រវត្តិជាយូរណាស់មកហើយ។ មជ្ឈត្តការ ត្រូវបានលើកយកមកនិយាយ នៅក្នុងអក្សរចំណាររបស់ក្រិចសម័យបុរាណ និងនៅក្នុងព្រះគម្ពីប៊ីប្ល័របស់សាសនាគ្រិស្ត។ មជ្ឈត្តការផ្នែកពាណិជ្ជកម្មទំនើបត្រូវបានបង្កើតឡើងជាលើកដំបូងនៅទ្វីបអឺរ៉ុបក្នុងយុគមជ្ឈឹមសម័យ។ ដោយសារពាណិជ្ជករធ្វើដំណើរក្នុងចំងាយ ដ៏ឆ្ងាយដើម្បីទៅធ្វើជំនួញនៅកន្លែងដែលពួកគេទិញ និងលក់ទំនិញ ព្រមទាំងសេវាកម្មផ្សេងៗ។ ដោយហេតុដំណើរមានគ្រោះថ្នាក់ច្រើន ហើយមានតំលៃថ្លៃ។ វិវាទនានាត្រូវដោះស្រាយអោយបានឆាប់រហ័សនិងនៅជិតទីកន្លែងធ្វើជំនួញនោះ។ យ៉ាងណាមិញ នៅពេលនោះតុលាការអចិន្ត្រៃយ៍មិនអាចដោះស្រាយវិវាទទាំងនោះអោយបានឆាប់រហ័សឡើយ និងគ្មានចំណេះដឹងពីបទដ្ឋានឧស្សាហកម្មរបស់អ្នកជំនួញឡើយ។ នេះគឺជាចំនុចសំខាន់ដោយសារបទដ្ឋានសឧស្សាហកម្មទាំងនោះត្រូវបានរបង្កើតឡើង ដើម្បីជួយសំរួលទំនាក់ទំនងពាណិជ្ជកម្មក្នុងចំណោមដែល

ភាគីដែលមកពីប្រទេស និងវប្បធម៌ផ្សេងៗគ្នា។ ដោយសមត្ថកិច្ចរបស់តុលាការនៅមានកំរិត ពាណិជ្ជករបានបង្កើតវេទិការធ្វើមជ្ឈត្តការជាឯកជន ដែលអាចដោះស្រាយដោយប្រសិទ្ធិភាព ហើយដែលជាញឹកញាប់តែងតែប្រាស់អ្នកជំនាញឧស្សាហាកម្ម និងបទដ្ឋានឧស្សាហាកម្មផង ដែរ។ នៅពេលដែលនិគមជនជាតិអង់គ្លេសផ្លាស់ទីលំនៅទៅទ្វីបអាមេរិកនៅអំឡុងសតវត្ស ទី១៧ និងទី១៨ ពួកគេបាននាំមកជាមួយខ្លួននូវបែបផែនមជ្ឈត្តការទាំងនេះផង។ ជាលទ្ធផល មជ្ឈត្តការបានដើរតួនាទីសំខាន់ នៅក្នុងដំណោះស្រាយផ្នែកពាណិជ្ជកម្មនៅក្នុងទឹកដីអាណា និគមអង់គ្លេសនៅក្នុងទ្វីបអាមេរិក។ ក្នុងឆ្នាំ ១៧៨៦ ស្ថាប័នមជ្ឈត្តការអចិន្រ្តៃយ៍ដំបូង បង្អស់ត្រូវបានបង្កើតឡើងដោយសភាពាណិជ្ជកម្មក្រុងញ៉ូយ៉ក។

លុះដល់សតវត្សទី២០ ដោយហេតុថាសំណុំរឿងក្តីដែលត្រូវធ្វើការដោះស្រាយចាប់ផ្តើមកើនឡើង តុលាការនៃប្រទេសជាច្រើន បានចាប់ផ្តើមទទួលយកមជ្ឈត្តការថាជាវិធីសាស្រ្តស្របច្បាប់មួយក្នុងដំណោះស្រាវិវាទ។ នៅក្នុងសហរដ្ឋអាមេរិក ច្បាប់ស្តីពីមជ្ឈត្តការរដ្ឋសហព័ន្ធឆ្នាំ១៩២៥ បានផ្តល់សុពលភាពដល់ " ខ " ដែលចែងស្តីពីមជ្ឈត្តការនៅក្នុងកិច្ចសន្យាពាណិជ្ជកម្មអោយធ្វើការអនុវត្តអោយបាន។ ប្រទេសផ្សេងៗ បានអនុវត្តតាមយ៉ាងឆាប់រហ័សដែលនាំអោយវេទិការធ្វើមជ្ឈត្តការមានការកើនឡើងយ៉ាងឆាប់រហ័ស នៅពាសពេញពិភពលោកទាំងមូល។ ក្នុងឆ្នាំ១៩២៣ សភាពាណិជ្ជកម្មអន្តរជាតិទីក្រុងប៉ារីស បានបង្កើតតុលាការមជ្ឈត្តការអន្តរជាតិ ដែលបានក្លាយជាវេទិការធ្វើមជ្ឈត្តការដែលល្បីល្បាញបំផុតនៅក្នុងពិភពលោក។ នៅសតវត្សកន្លងទៅនេះ កំនើនសេដ្ឋកិច្ចនៅអាស៊ីបាននាំឲ្យការមានការកើនឡើងដ៏គួរឲ្យកត់សំគាល់នៃវេទិការធ្វើមជ្ឈត្តការនៅអាស៊ី។ បច្ចុប្បន្នវេទិការនៅអាស៊ីដ៏ធំបំផុតចំនួន៣ រួមមាន គណៈកម្មការមជ្ឈត្តការផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិប្រទេសចិន មជ្ឈមណ្ឌលការផ្សេងៗអន្តរជាតិនៅទីក្រុងហុងកុង និងមជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសិង្ហបុរី។ ហើយក៏មានវេទិការធ្វើមជ្ឈត្តការផ្សេងៗនៅប្រទេសជប៉ុន ថៃ វៀតណាម ម៉ាឡេស៊ី តៃវ៉ាន់ ឥណ្ឌា និងឥណ្ឌូនេស៊ីផងដែរ។

### ២.ដំណើរការនៃនីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ដំណើរការនៃមជ្ឈត្តការអាចត្រូវបានគេផ្តួចផ្តើមតាមវិធី ៣យ៉ាងដូចជា:

-តាមរយៈកិច្ចព្រមព្រៀងផ្សះផ្សារបស់មជ្ឈត្តការ

-តាមរយៈការព្រមព្រៀងផ្សះផ្សាស្តីពីមជ្ឈត្តការនៅពេលមានវិវាទកើតឡើង

-តាមរយៈមជ្ឈត្តការដែលត្រូវបានបង្គាប់ដោយតុលាការ

ជាទូទៅកិច្ចព្រមព្រៀងផ្សះផ្សាស្តីពីមជ្ឈត្តការដែលមានស្រាប់ ឬមានចែងក្នុងកិច្ចសន្យាជាវិធីមួយដែលគេបំពេញនិយមប្រើបំផុត ព្រោះថាវាងាយ និងដោះស្រាយវិវាទបានឆាប់រហ័ស។

**ក.ការដាក់ពាក្យបណ្តឹង**

**ក.១.ការដាក់ពាក្យបណ្តឹងរបស់ភាគីអ្នកប្តឹងទាមទារ**

ប្រសិនបើគូភាគីមានកិច្ចព្រមព្រៀង មជ្ឈត្តការជាមុនស្រាប់ ដែលជាទូទៅជាផ្នែកមួយនៃកិច្ចសន្យាដើម ភាគីម្ខាងត្រូវបង្ហាញភាគីម្ខាងទៀតនូវសំណើរជាលាយល័ក្ខអក្សរ ដើម្បីធ្វើមជ្ឈត្តការ។ យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម សំណើរជាលាយល័ក្ខអក្សរនោះទៅប្រគល់ដល់ភាគីម្ខាងទៀតដោយផ្ទាល់ ឬទៅដល់ទីកន្លែងអាជីវកម្ម លំនៅស្ថានអចិន្ត្រៃយ៍ ឬអាស័យដ្ឋានប្រៃសណីយ៍របស់គាត់។ ភាគីដែលផ្តួចផ្តើមធ្វើ មជ្ឈត្តការហៅថា˝ ភាគីប្តឹង ˵ ហើយភាគីដែលទទួលសំណើរហៅថា ˝ ភាគីឆ្លើយតប ˵ ។ ដំណើរការមជ្ឈត្តកម្មចាប់ផ្តើមនៅពេលភាគីឆ្លើយតបបានទទួលសំណើរ។ អ្នកប្តឹងទាមទារត្រូវបញ្ជាក់នៅក្នុងពាក្យបណ្តឹងទាមទារដូចជា អង្គហេតុដែលគាំទ្រការទាមទារ ចំណុចជាក់លាក់នៃបញ្ហា និងសំណាងការខូចខាតដែលត្រូវទាមទារ។ នៅក្នុងវិធានមជ្ឈត្តការ UNCITRAL របស់អង្គការសហប្រជាជាតិការជូនដំណឹងអំពីមជ្ឈត្តការត្រូវរួមបញ្ចូលនូវចំនុចមួយចំនួនៈ

-ការទាមទារអោយមានការដោះស្រាយវិវាទដោយវិធានការមជ្ឈត្តការ

-សំណៅលើ ˝ ខ ˵ ស្តីពីមជ្ឈត្តការ ឬលើកិច្ចព្រមព្រៀងមជ្ឈត្តការដោយឡែកណាមួយដែលត្រូវយកមកអនុវត្ត

-សំណៅយោង ឬកិច្ចសន្យាដែលបង្ក ឬទាក់ទងនឹងវិវាទ

-ចរិតទូទៅនៃការទាមទារ និងការលើកឡើងអំពីចំនួនទឹកប្រាក់ដែលពាក់ព័ន្ធប្រសិនបើមាន

-ការអនុគ្រោះ ឬដំណោះស្រាយដែលចង់បាន

-សំណើរអំពីចំនួនអាជ្ញាកណ្តាល ( មួយ ឬបី ) ប្រសិនបើភាគីទាំងអស់មិនបានព្រមព្រៀងពីមុននោះទេ។

### ក.២. ការដាក់ពាក្យបណ្តឹងរបស់ដភាគីឆ្លើយតប

នៅពេលដែលភាគីប្តឹងដាក់ពាក្យបណ្តឹងរួច ភាគីឆ្លើយតបក៏ត្រូវដាក់ពាក្យបណ្តឹងរបស់ខ្លួនដែរ។យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងវិធានមជ្ឈត្តការ UNCITRAL ភាគីឆ្លើយតបត្រូវធ្វើពាក្យដោះសាររបស់ខ្លួនដែលឆ្លើយតបទៅនឹងចំនុចដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងទាមទារ ព្រមភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ និងបណ្តឹងតបដែលខ្លួនមានផង។ ករណីនេះមិនមានកំណត់ពេលវេលាឡើយសំរាប់ការធ្វើបណ្តឹងដោះសាររបស់ភាគីឆ្លើយតបទេ លើកលែងតែមានបញ្ជាក់ដោយមជ្ឈត្តករ។

## ខ. ដំណើរការនៃនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

### ខ.១. ការជ្រើសតាំងមជ្ឈត្តករ

ក្រោយពីប្តឹងទាមទារបានដាក់ជាបឋម ភាគីវិវាទត្រូវជ្រើសរើសមជ្ឈត្តការដើម្បីគ្រប់គ្រងដំណើរការដោះស្រាយវិវាទរបស់ខ្លួន។ ភាគីវិវាទមានសេរីភាពក្នុងការកំណត់ចំនួនមជ្ឈត្តករតាមតំរូវការ ក៏ប៉ុន្តែត្រូវកំណត់ចំនួនសេសមជ្ឈត្តករមិនត្រូវស្ថិតនៅក្នុងឋានានុក្រមជាមន្ត្រីនៃស្ថាប័ននីតិបញ្ញត្តិ ស្ថានប័ននីតិប្រតិបត្តិ និងតុលាការព្រមទាំងមិនធ្លាប់បានផ្តន្ទាទោសឰពីបទមជ្ឈឹម ឬបទឧក្រិដ្ឋណាមួយទេ។ ប្រសិនបើភាគីវិវាទមិនបានកំណត់ចំនួនមជ្ឈត្តករទេ មជ្ឈត្តករត្រូវមានចំនួនបី ( ៣ ) រូប។ មជ្ឈត្តករដែលបានជ្រើសរើស មិនត្រូវបានបដិសេធដោយសារមូលហេតុសញ្ជាតិទេ។

ករណីមជ្ឈត្តករមានចំនួន៣នាក់ ត្រូវបានជ្រើសរើសទៅតាមនីតិវិធីដូចតទៅ៖

-ភាគីនីមួយៗ ជ្រើសតាំងមជ្ឈត្តករ១នាក់ ហើយមជ្ឈត្តករទាំង២ ដែលត្រូវបានជ្រើសរើសដោយភាគីនីមួយៗធ្វើការជ្រើសតាំងមជ្ឈត្តករទី៣។

-ករណីភាគីវិវាទណាមួយពុំបានជ្រើសតាំងមជ្ឈត្តករក្នុងរយៈពេល ៣០ថ្ងៃ ក្រោយទទួលសំណើរជ្រើសតាំងពីភាគីវិវាទម្ខាងទៀត តុលាការ ឬមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវជ្រើសតាំងមជ្ឈត្តករតាមសំណើររបស់ភាគីវិវាទ។

ករណីមជ្ឈត្តករមាន១នាក់ ត្រូវបានជ្រើសរើសជាដំបូងផ្អែកលើការព្រមព្រៀងគ្នារវាងភាគីវិវាទ ប៉ុន្តែប្រសិនបើភាគីវិវាទមិនព្រមព្រៀងគ្នា តុលាការ ឬមជ្ឈត្តការជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវជ្រើសតាំងតាមសំណូមពររបស់គូវិវាទ។

មជ្ឈត្តករដែលបានជ្រើសតាំង ត្រូវបង្ហាញលក្ខណៈពិសេសដូចជា ភាពមិនលំអៀងឯករាជភាពរបស់ខ្លួនចាប់តាំងពីពេលដែលគេជ្រើសតាំងរហូតដល់ដំណើរការ។

យោងតាមក្រមសីលធម៌វិជ្ជាជីវៈ សំរាប់មជ្ឈត្តករនៅក្នុងវិវាទមជ្ឈត្តកម្ម ចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥មជ្ឈត្តករត្រូវអនុវត្តនូវគោលការណ៍ទាំង១០ នៃក្រមសីលធម៌ដូចជា៖

-គោលការណ៍ទី១ មជ្ឈត្តករត្រូវរក្សាភាពសុច្ចរិត និងយុត្តិធម៌នៃនីតិវិធីមជ្ឈត្តការ។

-គោលការណ៍ទី២ មជ្ឈត្តករត្រូវបង្ហាញអំពីផលប្រយោជន៍ ឬទំនាក់ទំនងណាមួយដែលប៉ះពាល់ដល់អនាគតិ។

-គោលការណ៍ទី៣ មជ្ឈត្តករគួរជៀសវៀងអំពើផ្តាំផ្ញើ ឬការស្តែងចេញនូវការផ្តាំផ្ញើក្នុងការប្រាស្រ័យទាក់ទងជាមួយភាគីវិវាទ។

-គោលការណ៍ទី៤ មជ្ឈត្តករត្រូវដឹកនាំដំណើរការដោយយុត្តិធម៌ និងសេចក្តីអំណត់ព្យាយាម។

-គោលការណ៍ទី៥ មជ្ឈត្តករគួរធ្វើសេចក្តីសំរេចក្នុងលក្ខណៈយុត្តិធម៌ ឯករាជ្យ និងល្អិតល្អន់។

-គោលការណ៍ទី៦ មជ្ឈត្តករត្រូវមានភាពស្មោះត្រង់ចំពោះទំនាក់ទំនងនៃទំនុកចិត្ត និងការក្សាការសំងាត់ដែលផ្សារភ្ជាប់នឹងមុខតំណែង។

-គោលការណ៍ទី៧ មជ្ឈត្តករគួប្រកាន់ភ្ជាប់បទដ្ឋាននៃសុច្ចរិតភាព និងយុត្តិធម៌នៅពេលរៀបចំសំរាប់ការ សងគុណ និងការទូទាត់ចំណាយផ្សេងៗ។

-គោលការណ៍ទី៨ មជ្ឈត្តករអាចធ្វើការឃោសនា ឬផ្សព្វផ្សាយអំពីសេវាកម្មមជ្ឈត្តការដែលសច្ចៈ និងពិតប្រាកដ។

-គោលការណ៍ទី៩ មជ្ឈត្តករដែលតែងតាំងឡើងដោយភាគីម្ខាង មានករណីកិច្ចកំណត់ និងបង្ហាញអំពី ឋានៈរបស់ខ្លួនព្រមទាំងអនុវត្តតាមក្រមនេះ វៀរលែងតែករណីលើកលែងដូចមានចែងនៅក្នុងគោលការណ៍ទី១០។

-គោលការណ៍ទី១០ អញ្ញត្រកម្មសំរាប់មជ្ឈត្តករដែលតែងតាំងដោយភាគីម្ខាង និងដែលមិនស្ថិតនៅក្រោមវិធានអព្យាក្រឹត្យភាព។

**ការបញ្ចប់អាណត្តិរបស់មជ្ឈត្តករះ**

-មជ្ឈត្តករដកខ្លួនចយពីមុខតំណែង

-ភាគីវិវាទឯកភាពគ្នាបញ្ចប់អាណត្តិ

-មជ្ឈត្តករបានបង្ហាញពីលក្ខណៈពិសេស ដែលបង្កអោយមានការសង្ស័យពីភាពមិនលំអៀង ឬឯករាជ្យភាព

-មជ្ឈត្តករមិនអាចបំពេញមុខងាររបស់ខ្លួនដោយសារមូលហេតុច្បាប់ ឬមូលហេតុជាក់ស្តែង ឬមូលហេតុផ្សេងទៀត។

ភាគីវិវាទអាចជំទាស់នឹងមជ្ឈត្តករដែលបានជ្រើសតាំង ប្រសិនបើមជ្ឈត្តករនោះត្រូវបានគេសង្ស័យថាប៉ះពាល់ដល់ភាពមិនលំអៀង ឬភាពឯករាជ្យ ឬមិនមានលក្ខណៈសម្បត្តិដូចដែលភាគីវិវាទបានព្រព្រៀង។ វិវាទដែលមានបំណងជំទាស់មជ្ឈត្តករ ត្រូវអនុវត្តតាមនីតិវិធីដូចជា៖

-បើភាគីវិវាទមិនមាមការឯកភាពលើនីតិវិធីជំទាស់ ភាគីវិវាទមួយដែលមានបំណងជំទាស់នឹងមជ្ឈត្តករត្រូវធ្វើរលិខិតបញ្ជាក់ពីមូលហេតុនៃការជំទាស់ ទៅវេទិកាមជ្ឈត្តកម្មក្នុងរយៈពេល១៥ថ្ងៃ ក្រោយថ្ងៃបង្កើត ឬក្រោយពេលដឹងថាមជ្ឈត្តករបានបំពាននូវភាពមិនលំអៀង និងឯករាជ្យភាព។ វេទិកាមជ្ឈត្តកម្មពាណិជ្ជកម្ម ត្រូវសំរេចលើការជំទាស់ លើកលែងតែមជ្ឈត្តករដកខ្លួន ឬភាគីវិវាទមួយទៀតឯកភាពលើការជំទាស់។

-ភាគីវិវាទអាចព្រមព្រៀង ឬមិនព្រមព្រៀងលើនីតិវិធីជំទាស់នឹងមជ្ឈត្តករ ភាគិវិវាទអាចសុំអោយតុលាការ ឬមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម សំរេចចុងក្រោយលើការជំទាស់ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីទទួលបានដំណឹងបដិសេធការជំទាស់។

### ខ.២. ដំណើរការមុនសវនាការ

-វិធានស្តីពីនីតិវិធី: គូវិវាទអាចព្រមព្រៀងលើវិធាននីតិវិធីរបស់ពួកគេក៏បាន ប៉ុន្តែប្រសិនបើគ្មានការព្រមព្រៀងនោះទេវេទិកាមជ្ឈត្តកម្មត្រូវដឹកនាំដំណើរការមជ្ឈត្តការក្នុងរបៀបមួយដែលខ្លួនយល់ថាត្រឹមត្រូវ។

-ទីកន្លែងធ្វើមជ្ឈត្តការ: ភាគីវិវាទមានសេរីភាពក្នុងការកំណត់ទីកន្លែងសំរាប់ធ្វើមជ្ឈត្តការនៅក្នុងកិច្ចព្រមព្រៀងរបស់ពួកគេ ឬនៅក្នុងលិខិតផ្សេងទៀត។ ក្នុងករណីដែលមិនបានព្រមព្រៀងគ្នាលើរឿងនេះ ទីកន្លែងធ្វើមជ្ឈត្តការត្រុវកំណត់វេទិការមជ្ឈត្តកម្ម ដោយពិចារណាអំពីកាលៈទេសៈនៃរឿងក្តី ហើយត្រូវមានការឯកភាពពីគូវិវាទ ឬក៏មានការព្រមព្រៀងផ្សេងពីនេះ។

-ភាសា: គូភាគីនៃវិវាទមានសេរីភាពក្នុងការយល់ព្រមលើភាសានៃដំណើរការមជ្ឈត្តការ។ ប្រសិនបើពួកគេមិនមានការព្រមព្រៀងគ្នា វេទិការមជ្ឈត្តកម្មនិងកំណត់។

-សន្ធានកម្ម: នៅមុនពេលចាប់ផ្តើមដំណើរការមជ្ឈត្តការជាផ្លូវការ វេទិការមជ្ឈត្តកម្មពិភាក្សាជាមួយគូវិវាតដើម្បីស្វែងរកលទ្ធភាពដំណោះស្រាយដោយស្ម័គ្រចិត្ត។ បើគូភាគីយល់ព្រមសះជា វេទិការមជ្ឈត្តកម្មត្រូវបានបញ្ចប់។

វិធានការបណ្តោះអាសន្ន: ដើម្បីធានាកុំអោយភស្តុតាងសំខាន់ៗមួយចំនួន អាចទទួលរងការខូចខាត ឬមានការបំផ្លាញចោល នោះភាគីអាចស្នើអោយវេទិកាមជ្ឈត្តកម្មចេញវិធានការបណ្តោះអាសន្ន ដោយអោយផ្តល់ប្រាក់ធានា ឬមិនផ្តល់។ ភាគីនីមួយៗ ក៏អាចស្វែងរកជំនួយពីតុលាការកម្ពុជាដើម្បីអោយចេញវិធានការបណ្តោះអាសន្ននៅមុន ឬកំពុងដំណើរការមជ្ឈត្តការ។

### ខ.៣. សវនាការមជ្ឈត្តការ

ជាទូទៅដំណើរការមជ្ឈត្តការ តំរូវឲ្យមានសវនាការមួយដូចគ្នាទៅនឹងដំណើរការជំនុំជំរះនៅក្នុងតុលាការ Common Law ដែរពោលគឺភាគីវិវាទតែងតែធ្វើសេចក្តីថ្លែងដែលបញ្ជាក់អំពីអង្គហេតុ នឹងអង្គច្បាប់។ បន្ទាប់មកអ្នកប្តឹងទាមទារ ឬភាគីប្តឹងធ្វើការបង្ហាញសាក្សីនិងឯកសារភស្តុតាងរបស់ខ្លួន ដែលសក្សីនោះត្រូវធ្វើការស្បថដូចនៅក្នុងដំណើរកាត់ក្តីនៅតុលាការដែរ។

ភាគីប្តឹង ឬមេធាវីរបស់ខ្លួននឹងសួរសំណួរដល់សាក្សីដែលមានវត្តមានដោយផ្ទាល់នៅចំពោះ មុខវេទិការមជ្ឈត្តកម្ម។ ពេលខ្លះវេទិការនឹងសួរបន្ថែមដែលស្រដៀងគ្នា និងចៅក្រមនៅក្នុងតុលាការកម្ពុជាដែរ។ ភាគីឆ្លើយក៏មានសិទ្ធិលើកសំណួរទៅសាក្សីភាគីប្តឹង ឬអ្នកប្តឹងទាមទារដែរ ដែលវិធាននេះមាននៅក្នុងប្រព័ន្ធច្បាប់Common Law ត្រូវបានគេហៅថា˝ការសាកសួរឆ្លើយ ˝។

ក្រោយពេលអ្នកប្តឹងទាមទារបានបង្ហាញខ្លួននូវភស្តុតាងរួចហើយ ភាគីឆ្លើយតបមាន

ឱកាសបង្ហាញសាក្សីរបស់ភាគីឆ្លើយតបបានដែរ។ បន្ទាប់មកគូភាគីនឹងផ្លាស់វេនគ្នាដើម្បីធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ ចំនែកវេទិការមជ្ឈត្តកម្មនឹងពិភាក្សាគ្នាដើម្បីចេញសេចក្ដីសំរេច។

យើងសង្កេតឃើញថា ដំណើរការនៃនីតិវិធីមជ្ឈត្តការមានលក្ខណៈបត់បែន និងទន់ភ្លន់ជាងនីតិវិធីនៅក្នុងតុលាការដោយហេតុថាប្រសិនបើមានការព្រមព្រៀងរវាងគូវិវាទ ការធ្វើសវនាការផ្ទាល់មិនចាំបាច់ប្រព្រឹត្តិឡើង ក៏បានដោយគ្រាន់តែធ្វើការបង្ហាញភស្តុតាងជាឯកសារ និងធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ជាលាយលក្ខអក្សរដាក់ជូនវេទិការមជ្ឈត្តការដើម្បីធ្វើការពិចារណា។ ប៉ុន្តែបើមានការស្នើអោយមានសវនាការដោយផ្ទាល់មាត់ ដោយភាគីវិវាទនោះសវនាការនឹងត្រូវប្រព្រឹត្តិឡើងដែរ។

**គ.ការធ្វើមជ្ឈត្តវិនិច្ឆ័យ**

ការធ្វើមជ្ឈត្តវិនិច្ឆ័យរបស់វេទិការមជ្ឈត្តកម្មដោយផ្ដោតសំខាន់ទៅលើះ

-សមធម៌ ឬតាមស្រុះស្រួលដែលបានអនុញ្ញាតច្បាស់លាស់ពីគូវិវាទ និង

-តាមទំលាប់ពាណិជ្ជកម្មដែលអនុវត្តចំពោះមុខជំនួញ

ការធ្វើសេចក្ដីសំរេចដែលមានមជ្ឈត្តករលើសពីម្នាក់ មជ្ឈត្តវិនិច្ឆ័យរបស់វេទិការមជ្ឈត្តកម្មត្រូវធ្វើ ឡើងដោយសំលេងភាគច្រើនដោយប្រៀបនឹងមជ្ឈត្តករដែលជាសមាជិកនៃវេទិការមជ្ឈត្តកម្ម។

ដើម្បីភ្ជាប់កាតព្វកិច្ច និងដើម្បីអោយអនុវត្តបានតាមរយៈរបស់តុលាការមជ្ឈត្តវិនិច្ឆ័យត្រូវះ

-ធ្វើជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយមជ្ឈត្តករ

-បញ្ជាក់ពីហេតុផលដែលចេញមជ្ឈត្តវិនិច្ឆ័យ

-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់សោហ៊ុយសំរាប់ការចំណាយលើមជ្ឈត្តការ

-បញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងសំរាប់ធ្វើមជ្ឈត្តការ

-ភាគីនីមួយៗត្រូវទទួលបានមជ្ឈត្តវិនិច្ឆ័យដែលមានចុះហត្ថលេខាមួយច្បាប់

**ឃ. ការបញ្ចប់ដំណើរការមជ្ឈត្តការ**

ដំណើរការមជ្ឈត្តការត្រូវបានបញ្ចប់នៅពេលៈ

-ធ្វើមជ្ឈត្តវិនិច្ឆ័យជាស្ថាពរ

-ភាគីប្តឹងទាមទារដកពាក្យបណ្តឹងទាមទាររបស់ខ្លួន ( ករណីគ្មានការបដិសេធពីភាគីឆ្លើយតប )

-ភាគីវិវាទឯកភាពគ្នាអោយបញ្ចប់ដំណើរការមជ្ឈត្តការ

-មានមូលហេតុផ្សេងទៀតដែលមិនអាចអោយដំណើរការបន្តទៀតដូចជា: ភាគីប្តឹងមិនបានបញ្ជាក់អំពីអង្គហេតុដែលគាំទ្រការទាមទារ បញ្ហាជាក់លាក់នៃវិវាទ និងការទាមទារទៅលើបណ្តឹងទាមទាររបស់ខ្លួន។

## IV. ការបញ្ចប់ដំណើរមជ្ឈត្តការ

### ១. គុណសម្បត្តិ

- អំពីពេលវេលា

ការយឺតយ៉ាវដែលកើតមាននៅក្នុងការដោះស្រាយជំលោះនៅក្នុងប្រព័ន្ធតុលាការ គឺជាហេតុផលដ៏សំខាន់នៅក្នុងការពិចារណាដោះស្រាយជំលោះក្រៅប្រព័ន្ធតុលាការ គឺជាហេតុផលដ៏សំខាន់នៅក្នុងការពិចារណាដំណោះស្រាយជំលោះក្រៅប្រព័ន្ធតុលាការ។ ជាទូទៅ ការដោះស្រាយក្រៅប្រព័ន្ធតុលាការមានឆាប់រហ័ស ដោយសារតែវាមានលក្ខណៈមិនស្មុគស្មាញការដូចជាការចរចា និងសន្ទានកម្មជាដើម គឺមានរយៈពេលតែមួយភាគតែប៉ុណ្ណោះនៃរយៈពេលដែលប្រើនៅក្នុងរឿងក្តីនៅក្នុងតុលាការ មួយផ្នែកដោយសារតែភាគីមានរយៈពេលឆាប់រហ័ស

ដែរ ដោយហេតុថាប្រព័ន្ធមជ្ឈត្តវិនិច្ឆ័យភាគច្រើន ត្រូវបានតាក់តែងឡើងដើម្បីលើកស្ទួយអោយមានពេលវេលារហ័ស។

-ចំណេះដឹងជាឯកទេស

ហេតុផលមួយទៀតក្នុងការពិចារណាដំណោះស្រាយជំលោះក្រៅប្រព័ន្ធតុលាការ គឺវិធីនេះអនុញ្ញាតអោយគូភាគីជ្រើសរើសភាគីអព្យាក្រឹត្យ ដែលមានចំណេះដឹងឯកទេសនៅក្នុងសាច់រឿងរបស់ពួកគេ។ សូម្បីតែមជ្ឈត្តវិនិច្ឆ័យ ក៏អាចមានរយៈពេលឆាប់រហ័សដែរដោយហេតុថាប្រព័ន្ធមជ្ឈត្តវិនិច្ឆ័យភាគច្រើន ត្រូវបានតាក់តែងឡើងដើម្បីលើកស្ទួយអោយមានពេលវេលាឆាប់រហ័ស។

-សោហ៊ុយចំណាយ

ជាទូទៅដំណោះស្រាយនៃជំលោះក្រៅប្រព័ន្ធតុលាការ ចុះសោហ៊ុយតិចជាងការដោះស្រាយតាមផ្លូវតុលាការដោយសារតែមានរយៈពេលខ្លី មិនទាមទារអោយបង់ប្រាក់ប្រដាប់ក្តី ហើយភាគីក៏មិនចាំបាច់ចំណាយប្រាក់ក្នុងការជួលមេធាវីដូចនៅតាមផ្លូវតុលាការទេ។

-ភាពអាថិកំបាំង

ដំណោះស្រាយជំលោះក្រៅប្រព័ន្ធតុលាការ មានអត្ថប្រយោជន៍ជាសក្តានុភូតមួយផងដែរលើដំណោះស្រាយជំលោះតាមផ្លូវតុលាការ គឺការរក្សាអាថិកំបាំងបានល្អ ដោយសារតែវាមិនចាំបាច់អោយមានការបើសវនាការជាសាធារណៈ។
នៅក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ យើងមិនចាំបាច់អោយមានមេធាវីសំរាប់ការពារក៏បាន តែទោះជាមានការចូលរួមពីមេធាវី ក៏សេចក្តីសំរេចនៃវិវាទនៅតែមានលក្ខណៈសំងាត់ ដែលប្រការនេះអាចមានសារៈសំខាន់យ៉ាងខ្លាំងសំរាប់កិត្តិយសរបស់ភាគីវិវាទ និងអាជីវកម្មរបស់គេផងដែរ។

-លទ្ធភាពគ្រប់គ្រង់របស់ភាគី

ការចរចាផ្តល់លទ្ធភាពអោយគូភាគីអាចគ្រប់គ្រងយ៉ាងពេញលេញ ទៅលើដំណើរការ និងការបញ្ចប់។ ភាគីវិវាទជាអ្នកកំណត់ថាតើភាគីវិវាទត្រូវធ្វើការចរចារបៀបណា និងថាតើនឹងមានការស្រុះស្រួលឬទេ។ នៅក្នុងការចរចាគេមិនអាចបង្ខំភាគីណាមួយអោយចូលក្នុងដំណើរការ ឬការស្រុះស្រួលណាមួយដោយគ្មានការព្រមព្រៀងពីភាគីណាមួយ។

-រក្សាទំនាក់ទំនង

ការដោះស្រាយជំលោះក្រៅប្រព័ន្ធតុលាការ អនុញ្ញាតអោយភាគីរៀបចំដំណោះស្រាយមួយដែលអាចរក្សាសម្ព័ន្ធភាពរបស់ពួកគេជាបន្តទៅទៀត។ ទោះបីជាមជ្ឈត្តការមានទិដ្ឋភាពបដិបក្ខក៏ដោយ ជាទូទៅមជ្ឈត្តការមានភាពបដិបក្ខតិចជាងដំណើរការបណ្តឹងនៅតុលាការ។ កត្តានេះអាចជួយរក្សាទំនាក់ទំនងរវាងគូភាគីបាន។

**២. គុណវិបត្តិ**

-សេចក្តីសំរេច

សេចក្តីសំរេចនៅក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ មានលក្ខណៈមិនសូវជាផ្លូវការ ហើយមិនមានលក្ខណៈចាប់បង្ខំអោយគូភាគីត្រូវតែគោរពតាមនោះទេ លើកលែងតែមជ្ឈត្តវិនិច្ឆ័យដែលមានលក្ខណៈចាប់បង្ខំ។

-ភាពឯកជន

ដោយសារតែការដោះស្រាយជំលោះក្រៅប្រព័ន្ធតុលាការមានលក្ខណៈឯកជនហួសហេតុពេក អាចបណ្តាលអោយភាគីម្ខាងទទួលរងនូវការគំរាមគំហែង ពីភាគីម្ខាងទៀតដែលមានអំណាចធំជាង ដោយសារតែវាមិនតំរូវអោយមានការបើកសវនាការជាសាធារណៈដូចការដោះស្រាយតាមផ្លូវតុលាការ។

-ពេលវេលា

ថ្វីត្បិតតែការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ ប្រើប្រាស់ពេលវេលាខ្លីជាងតាមផ្លូវតុលាការ ក៏ដោយ ប៉ុន្តែប្រសិនបើភាគីណាមួយមានបំណងចង់អូសបន្លាយពេលវេលាដើម្បីផលប្រយោជន៍អ្វីមួយរបស់គេនោះការដោះស្រាយវិវាទនោះក៏មានរយៈពេលអូសបន្លាយវែងទៅតាមនោះដែរ។